សមាជរដ្ឋសភា និងព្រឹទ្ធសភា

# សេចក្តីថ្លែងការណ៍

## សមាជរដ្ឋសភា និងព្រឹទ្ធសភា គាំទ្រចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជា លើបញ្ហាព្រំដែន ជាមួយព្រះរាជាណាចក្រថៃ ក្រោយហេតុការណ៍វាយប្រហារប្រដាប់អាវុធ នៅតំបន់មុំបី ក្នុងទឹកដីកម្ពុជា

អង្គសមាជរដ្ឋសភា និងព្រឹទ្ធសភា វាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងយ៉ាងមោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការការពារឱ្យបានដាច់ខាតនូវឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់យន្តការការទូត ការចរចា យន្តការតំបន់ អង្គការសហប្រជាជាតិ តុលាការអន្តរជាតិ និងការប្រើប្រាស់សិទ្ធិស្វ័យការពារខ្លួន។ រាជរដ្ឋាភិបាលកម្ពុជាកំពុងបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់ប្រកបដោយឆន្ទៈយ៉ាងមោះមុត និងឥតងាករេ ក្នុងកិច្ចខិតខំប្រឹងប្រែងរក្សាសុខសន្តិភាព ស្ថិរភាព និងឧត្តមប្រយោជន៍ស្នូលរបស់ជាតិ ដែលជាមរតកមិនអាចកាត់ថ្លៃបានរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងរយៈពេលជាង៤០ឆ្នាំ កន្លងមកនេះ។

អង្គសមាជប្រកាសថ្កោលទោស ចំពោះសកម្មភាពវាយប្រហារខុសច្បាប់ដោយកងទ័ពថៃមកលើកងទ័ពកម្ពុជា នៅតំបន់មុំបី ក្នុងទឹកដីកម្ពុជា កាលពីព្រឹកថ្ងៃទី២៨ ខែឧសភា កន្លងទៅនេះ។ ការវាយប្រហារនេះ ជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអធិបតេយ្យ និងបូរណភាពទឹកដី របស់ព្រះរាជាណាចក្រកម្ពុជា។

ផ្អែកលើហេតុផលខាងលើនេះ អង្គសមាជគាំទ្រពេញទំហឹង ចំពោះគោលជំហរច្បាស់លាស់ និងម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាល ក្នុងការយកបញ្ហា **ប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច ប្រាសាទតាក្របី និងតំបន់មុំបី** ដែលកន្លងទៅរមែងមានភាពកកាំកកូស ដែលបង្កឡើងដោយកងទ័ពថៃនោះ ទៅដោះស្រាយនៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ) ដើម្បីពន្លត់និងបញ្ចប់បញ្ហានេះ ដោយសំឡេងអនុម័តជាឯកច្ឆ័ន្ទ ១៨២ លើ ១៨២ សំឡេង នៃសមាជិកចូលរួមទាំងអស់ នាថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៥។ អង្គសមាជគាំទ្រពេញទំហឹង ចំពោះប្រសាសន៍**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានលើកឡើងថា **«ត្រូវពន្លត់ភ្លើងជាជាងអង្គុយបក់ផ្សែង»**។

អង្គសមាជក៏បានសង្កត់ធ្ងន់អំពីការថែរក្សាទំនាក់ទំនងជាប្រក្រតី និងល្អប្រសើររវាងប្រទេស និងប្រជាជនទាំងពីរ ហើយចៀសវាងការពង្រីកជម្លោះ ដែលនាំមកនូវអវិភាពរវាងប្រទេស និងប្រជាជនទាំងពីរ។ អង្គសមាជលើកទឹកចិត្តដល់រាជរដ្ឋាភិបាលបន្តប្រើប្រាស់ឱ្យអស់លទ្ធភាពនូវយន្តការទ្វេភាគី ដែលមានស្រាប់



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ២១១ ៤៤១, ២១១ ៤៤២, ២១១ ៤៤៣ ទូរសារ: (៨៥៥-២៣) ២២១ ៤៤៦, E-mail: secretariat@senate.gov.kh

រួមមាន គណៈកម្មការចម្រុះព្រំដែន (JBC) និងគណៈកម្មាធិការព្រំដែនទូទៅ (GBC) ដើម្បីរក្សា និងកសាងព្រំដែនមិត្តភាព សន្តិភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ ជាប្រយោជន៍សម្រាប់ប្រទេស និងប្រជាជនទាំងពីរ។

អង្គសមាជថ្លែងអំណរគុណ និងកោតសរសើរចំពោះវីរភាពរបស់កងទ័ព កងនគរបាលជាតិ និងគ្រប់បណ្តាកងកម្លាំង ដែលឈរជើងការពារបូរណភាពទឹកដី នៅតាមបណ្តោយព្រំដែន។ អង្គសមាជក៏បានបំផុសចលនាខឿនការពារជាតិរបស់ប្រជាជន តាមរយៈការផ្តល់ការគាំទ្រដោយស្ម័គ្រចិត្តតាមគ្រប់រូបភាព ដើម្បីលើកទឹកចិត្តដល់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ក្នុងការបំពេញភារកិច្ចការពារបូរណភាពទឹកដី។

អង្គសមាជអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់និន្នាការទាំងអស់ ទាំងក្នុងនិងក្រៅប្រទេស រួបរួមជាធ្លុងមួយ ជឿទុកចិត្តលើរាជរដ្ឋាភិបាល ក្នុងស្មារតីសាមគ្គីជាតិ ឯកភាពជាតិ ដើម្បីពង្រឹងខឿនការពារជាតិ និងដើម្បីទប់ស្កាត់ និងបំផ្លាញមហិច្ឆតានយោបាយរបស់ក្រុមជ្រុលនិយមមួយក្តាប់តូច ដែលយកបញ្ហាព្រំដែនជារបៀបវារៈបម្រើនយោបាយទុច្ចរិតរបស់ខ្លួន៕

ថ្ងៃចន្ទ ៧កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៥

**ប្រធានសមាជ**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**